# ច្បាប់

## ស្តីពី

## វិសោធនកម្មមាត្រា៣៦ មាត្រា៣៨ មាត្រា៩០ និងមាត្រា៩១ នៃ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

# ព្រះរាជក្រម

នស/រកម/០១០២/០០៥

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## ពុទ្ធបរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ២១ក្រ. ចុះថ្ងៃទី០៨ ខែ មីនា ឆ្នាំ១៩៩៣

-បានទ្រង់យល់បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ដែលប្រកាសឱ្យប្រើដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (SNC) ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩២

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជានិងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីវិសោធនកម្មមាត្រា ៣៦ មាត្រា៣៨ មាត្រា៩០ និងមាត្រា៩១ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែ វិច្ឆិកាឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ហើយដែលមាន សេចក្តីទាំងស្រុងដូចតទៅ :

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០
# និងមាត្រា ៩១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ

**មាត្រាតែ ១.-**

មាត្រា ៣៦ មាត្រា ៣៨ មាត្រា ៩០ និងមាត្រា ៩១. នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ២១ក្រ ចុះថ្ងៃទី ០៨ ខែមីនា ឆ្នាំ១៩៩៣ ដោយក្រុមប្រឹក្សារដ្ឋនៃរដ្ឋកម្ពុជា ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ៣៦ ថ្មី.-**

ចាត់ទុកជាមន្ត្រីនគរបាលយុត្តិធម៌ ឬអាចបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌រួមមាន :

១-ព្រះរាជអាជ្ញានិងចៅក្រមស៊ើបអង្កេត "ក្នុងភារកិច្ចតែប៉ុណ្ណោះ"

២-អភិបាល អភិបាលរង ខេត្ត ក្រុង អភិបាល អភិបាលរងស្រុក ខ័ណ្ឌ និង មេឃុំ ចៅសង្កាត់

៣-ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និងប្រធាន. អនុប្រធានផ្នែកនៃ :

-នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ

-នាយកដ្ឋាននគរបាលសេដ្ឋកិច្ច

-នាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ.

-នាយកដ្ឋានប្រឆាំងភេរវកម្ម

-នាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន"

-នាយកដ្ឋានជនបរទេស

-មន្ទីរប្រឆាំងគ្រឿងញៀន

៤-ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង

៥-ប្រធាន អនុប្រធានការិយាល័យ និងប្រធាន អនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្តក្រុងដូចជា :

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល

-ការិយាល័យនគរបាលសេដ្ឋកិច្ច

-ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

-ការិយាល័យប្រឆាំងគ្រឿងញៀន

-ការិយាល័យប្រឆាំងភេរវកម្ម

-ការិយាល័យជនបរទេស

៦-អធិការ អធិការរង និងប្រធាន អនុប្រធានផ្នែកព្រហ្មទណ្ឌនៃ អធិការដ្ឋាននគរបាលស្រុក ខណ្ឌ

៧-ប្រធាន អនុប្រធានការិយាល័យនគរបាលចរាចរ និងប្រធាន អនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរ"

៨-ប្រធាន អនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាល ឃុំ សង្កាត់ ចំពោះបទល្មើសព្រហ្មទណ្ឌ

៩-មេបញ្ជាការ មេបញ្ជាការរង ព្រមទាំងមន្ត្រីចាប់ពីអនុប្រធានផ្នែកឡើងនៃកងរាជអាវុធហត្ថដែលទទួលការងារព្រហ្មទណ្ឌ "ចំពោះបទល្មើសដែលពាក់ព័ន្ធនឹងកិច្ចការយោធា"

១០-មន្ត្រីនៃក្រសួងឬស្ថាប័នណាដែលច្បាប់បានប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើស

ប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវមានការដឹកនាំនិងសម្របសម្រួលរបស់ព្រះរាជអាជ្ញាលើនីតិវិធីនិងវិធានស៊ើបអង្កេតដើម្បីធានាការចោទប្រកាន់ឱ្យមានប្រសិទ្ធិភាព ក្រោមការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានសិទ្ធិប្រគល់ទៅមន្ត្រីនគរបាលយុត្តិធម៌នូវសមត្ថកិច្ចណាមួយដែលមានវិសាលភាពលើដែនដីទាំងមូល ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ចេញ

ប្រកាសណែនាំអំពីរបៀបរបបធ្វើការងារនិងនីតិវិធីខាងផ្លូវរដ្ឋបាលដល់មន្ត្រីនគរបាលយុត្តិធម៌ ។

អភិបាល អភិបាលរង ខេត្ត ក្រុង អភិបាល អភិបាលរងស្រុក ខ័ណ្ឌនិង មេឃុំ ចៅសង្កាត់មានសមត្ថកិច្ចបញ្ជាណែនាំមន្ត្រីនគរបាលយុត្តិធម៌ដែលស្ថិតក្នុងវង្វង់ដែនដីរបស់ខ្លួនគ្រប់គ្រងឱ្យធ្វើប្រតិបត្តិការលើបទល្មើសបាន ហើយប្រតិបត្តិការទាំងឡាយត្រូវមានសហការពីព្រះរាជអាជ្ញា ។

**មាត្រា ៣៨ ថ្មី.-**

មន្ត្រីនគរបាលយុត្តិធម៌

-ទទួលពាក្យបណ្តឹងទាមទារ បណ្តឹងបរិហារ ព្រមទាំងរបាយការណ៍នគរបាលយុត្តិធម៌ទាក់ទងបទឧក្រិដ្ឋ បទមជ្ឈិមនិងបទលហុនានា

-ចាត់ចែងប្រមូលភស្តុតាងនានា

-អាចស្នើសុំជំនួយពីកម្លាំងសាធារណៈ

-ធ្វើកំណត់ហេតុ

-អាចទទួលលិខិតបង្គាប់ឱ្យសួរជំនួស

-អាចសម្រេចឃាត់ខ្លួនបានរយៈពេល ៤៨ម៉ោង យ៉ាងយូរ

-ក្នុងករណីរឿងឧក្រិដ្ឋនិងមជ្ឈិមជាក់ស្តែង អាចសួរយកចម្លើយសាក្សីធ្វើការឆែកឆេរនិងរឹបអូសវត្ថុតាង អាចចាត់តាំងអ្នកជំនាញសម្រេចឃាត់ខ្លួនជនល្មើស "៤៨ម៉ោងយ៉ាងយូរ" ឃាត់ខ្លួនបុគ្គលណាប្រសិនបើមានភស្តុតាង ឬមានការសង្ស័យដែលមានមូលដ្ឋានច្បាស់សមស្របធ្វើការចោទប្រកាន់បាន

-មន្ត្រីនគរបាលយុត្តិធម៌អាចសុំពន្យារពេលឃាត់ខ្លួនជនសង្ស័យបានក្នុងរយៈពេលមិនលើសពី ២៤ម៉ោង ដោយមិនគិតពីថេរវេលាចាំបាច់នៃការដឹកជញ្ជូនក្នុងល័ក្ខខ័ណ្ឌទាំង ៥ ដូចខាងក្រោម :

១-បទឧក្រិដ្ឋធ្ងន់ធ្ងរ

២-មានតម្រុយចង្អុលបង្ហាញច្បាស់ថាបានប្រព្រឹត្តបទល្មើស

៣-ជាវិធានការចាំបាច់ដើម្បីធ្វើឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ

៤-ពាក្យសុំត្រូវធ្វើជាលាយលក្ខណ៍អក្សរទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ភាពសមហេតុផល

៥-មានចំណារយល់ព្រមពីព្រះរាជអាជ្ញា ។

ការអនុញ្ញាតឱ្យពន្យារត្រូវដាក់បញ្ចូលក្នុងសំណុំរឿង ។

-ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ចំពោះបុគ្គលដែលត្រូវឃាត់ខ្លួននោះ មានអាយុតិចជាង ១៨ឆ្នាំ

-អនីតិជនដែលមានអាយុតិចជាង ១៣ឆ្នាំ មិនអាចត្រូវឃាត់ខ្លួនដល់ ៣៦ ម៉ោង ឡើយ ។

**មាត្រា ៩០ ថ្មី.-**

កាលបើចៅក្រមស៊ើបអង្កេតឃើញថា ហេតុការណ៍ដែលកើតមានមិនចូលជាបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ឬក៏គ្មានបន្ទុកគ្រប់គ្រាន់ទៅលើជនល្មើស អំពីបទចោទនោះ ចៅក្រមស៊ើបអង្កេតមានសិទ្ធិសម្រេចចេញដីកាលើកលែងចោទប្រកាន់ ។ តាមគោលការណ៍ ដីការបស់ចៅក្រមស៊ើបអង្កេតត្រូវលើកមូលហេតុនៃការសម្រេចរបស់ខ្លួន ។

ដីកានេះត្រូវជូនទៅព្រះរាជអាជ្ញាភ្លាម ព្រមទាំងសំណុំរឿងដើម្បីឱ្យព្រះរាជអាជ្ញាប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ក្នុងរយៈពេល ២៤ម៉ោង ។ ប្រសិនបើមានបណ្តឹងតវ៉ារបស់ព្រះរាជអាជ្ញានោះ ជនជាប់ចោទជាប់ឃុំឃាំង ត្រូវនៅជាប់ឃុំឃាំងដដែល ។ ផ្ទុយទៅវិញ បើគ្មានការតវ៉ារបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមស៊ើបអង្កេតចេញដីកាឱ្យដោះលែងជនជាប់ចោទ ប្រសិនបើជននេះគ្មានត្រូវជាប់ឃុំពីមូលហេតុអ្វីផ្សេងទៀតនោះ។

ដីកាលើកលែងចោទប្រកាន់នេះត្រូវជូនដំណឹងទៅដើមបណ្តឹង ឬតំណាងដើមបណ្តឹងមិនលើសពី ៧ថ្ងៃ ។ ក្នុងករណីដែលដើមបណ្តឹង ឬតំណាងដើមបណ្តឹងមិនសុខចិត្តទេនោះ អាចធ្វើពាក្យប្តឹងឧទ្ធរណ៍នៅការិយាល័យក្រឡាបញ្ជីនៃតុលាការនោះចាប់ពីថ្ងៃដែលបានទទួលដំណឹង ។

ក្នុងករណីដែលអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍យល់ព្រមតាមការតវ៉ារបស់ដើមបណ្តឹង ឬតំណាងដើមបណ្តឹង អគ្គព្រះរាជអាជ្ញាត្រូវបង្គាប់ឱ្យព្រះរាជអាជ្ញាតុលាការខេត្ត ក្រុង ឬតំណាងអយ្យការផ្សេងទៀតធ្វើការចោទប្រកាន់ ។

ដីកាលើកលែងចោទប្រកាន់ត្រូវជូនដំណឹងទៅដើមបណ្តឹង ឬតំណាងដើមបណ្តឹងមិនលើសពី ៧ថ្ងៃ ។ ក្នុងករណីដែលដើមបណ្តឹង ឬតំណាងដើមបណ្តឹងមិនសុខចិត្តទេនោះ អាចធ្វើពាក្យតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដោយផ្ទាល់ ឬតាមរយៈមេធាវីចាប់ពីថ្ងៃបានទទួលដំណឹង ។

មាត្រា ៩១ ថ្មី.-

ប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី ដីកាលើកលែងចោទប្រកាន់ដែលមានការឯកភាពពីព្រះរាជអាជ្ញាផងនោះ ត្រូវជូនដំណឹងដល់ភាគីដើមបណ្តឹងនោះ ។ ក្នុងរយៈពេល ៦០ថ្ងៃ គិតពីថ្ងៃបានទទួលដំណឹង ភាគីដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិប្តឹងតវ៉ាទៅសាលាឧទ្ធរណ៍ ។

ដីកាលើកលែងចោទប្រកាន់នេះ ត្រូវចម្លងជូនទៅមន្ត្រីនគរបាលយុត្តិធម៌មូលដ្ឋាន ។

ប្រសិនបើសាលាឧទ្ធរណ៍បដិសេធដីកាលើកលែងចោទប្រកាន់ ប្រធានសាលាឧទ្ធរណ៍អាចចេញដីកាចាប់ខ្លួនជនជាប់ចោទជាថ្មី ហើយយកមកឃុំខ្លួនបណ្តោះអាសន្នបាន កាលណាជនជាប់ចោទនៅក្រៅឃុំ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

**ប្រមុខរដ្ឋស្តីទី**

នរស.០២.០១.០០៧

**ហត្ថលេខា**

**ជា ស៊ីម**

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

លេខ : ១៣ ច.ល

**ស ខេង , យូ ហុកគ្រី**

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**